ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ........................................................

# សុន្ទរកថាបើក

## លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាលធនាគារជាតិនៃកម្ពុជា
## ថ្លែងក្នុងឱកាសបើកសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២៤ របស់ធនាគារជាតិនៃកម្ពុជា

**ថ្ងៃសុក្រ ១៤កើត ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨**

**ធនាគារជាតិនៃកម្ពុជា ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០២៤**

៚៚៚✻៛៛៛

**សូមគោរព៖**

- **គណៈអធិបតី**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំមានក្ដីសោមនស្សរីករាយជាអនេក និងសូមស្វាគមន៍ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ដែលបានចូលរួមក្នុងសន្និបាតបូកសរុបលទ្ធផលការងាររបស់ធនាគារជាតិនៃកម្ពុជាប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០២៤។ សន្និបាតរបស់យើងត្រូវបានរៀបចំឡើង ក្នុងគោលបំណងអបអរសាទរនិងផ្សព្វផ្សាយលទ្ធផលការងារដែលធនាគារជាតិនៃកម្ពុជាសម្រេចបានក្នុងឆមាសទី១កន្លងទៅ និងដាក់ចេញទិសដៅការងារសម្រាប់ឆមាសទី២។

នៅឆមាសទី១ ឆ្នាំ២០២៤ សេដ្ឋកិច្ចពិភពលោកបានបន្តកើនឡើងជាមួយបញ្ហាប្រឈម និងភាពមិនប្រាកដប្រជាខ្ពស់ ជាពិសេសបញ្ហាភូមិសាស្ត្រនយោបាយ។ សង្គ្រាមរុស្ស៊ី-អ៊ុយក្រែន និងអ៊ីស្រាអែល-ក្រុមហាម៉ាសនៅមជ្ឈិមបូព៌ានៅតែបន្តអូសបន្លាយ ដែលបានប៉ះពាល់ដល់អាយុជីវិតនិងជីវភាពរស់នៅរបស់ប្រជាជនជាច្រើនលាននាក់ ព្រមទាំងធ្វើឱ្យទំនាក់ទំនងការទូត និងសេដ្ឋកិច្ចរវាងបណ្ដាប្រទេសធំៗមួយចំនួនមានភាពល្អក់កករកាន់តែខ្លាំង។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ភាពតានតឹងភូមិសាស្ត្រនយោបាយទាំងនេះគឺជាឧបសគ្គដល់សន្ទុះការវិនិយោគនិងពាណិជ្ជកម្ម ព្រមទាំងបង្កើនភាពមិនច្បាស់លាស់លើការកើនឡើងនៃអតិផរណា។ ក្នុងស្ថានភាពនេះ បើទោះជាអតិផរណាបានថយចុះជាបន្តបន្ទាប់ក៏ដោយ ក៏បណ្តាធនាគារកណ្តាលធំៗមួយចំនួន ជាពិសេស ធនាគារកណ្តាលអាមេរិកមិនទាន់កាត់បន្ថយអត្រាការប្រាក់គោលរបស់ខ្លួននៅឡើយទេ។ បញ្ហាភូមិសាស្ត្រនយោបាយ ភាពមិនប្រាកដប្រជា និងបញ្ហាដែលបានកើតឡើងនៅក្នុងស្រុក បានធ្វើឱ្យតំបន់នានាលើពិភពលោកទទួលបានកំណើនក្នុងល្បឿនខុសៗគ្នា។ យ៉ាងណាមិញ នៅសហភាពអឺរ៉ុប កំណើនសេដ្ឋកិច្ចត្រូវបានប៉ាន់ស្មានថាសម្រេចបានក្នុងអត្រាទាប។ នៅប្រទេសចិន វិបត្តិអចលនទ្រព្យ ភាពតានតឹងពាណិជ្ជកម្មជាមួយសហរដ្ឋអាមេរិកនិងសហភាពអឺរ៉ុប កត្តាប្រជាសាស្ត្រ និងការកើនឡើងនៃថ្លៃពលកម្ម បាន និងកំពុងបន្ថយល្បឿនកំណើនសេដ្ឋកិច្ច ដែលបញ្ហានេះនាំឱ្យប៉ះពាល់ដល់ការងើបឡើងនៃសេដ្ឋកិច្ចតំបន់និងពិភពលោកផងដែរ។ ដោយឡែក សេដ្ឋកិច្ចសហរដ្ឋអាមេរិកមានវឌ្ឍនភាពល្អ ដោយសារការកើនឡើងនៃតម្រូវការក្នុងស្រុកនិងការចំណាយសាធារណៈ ទោះបីជានយោបាយរូបិយវត្ថុរឹតត្បិតត្រូវបានបន្តអនុវត្ត។

នៅកម្ពុជា ការដាក់ចេញឱ្យអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ នៃរាជរដ្ឋាភិបាលអាណត្តិថ្មី ដែលមាន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាប្រមុខរាជរដ្ឋាភិបាល កំពុងត្រូវបានអនុវត្តដោយពិលាសដែលបានជ្រោងសេដ្ឋកិច្ចកម្ពុជាឱ្យបន្តកើនឡើងប្រមាណ ៦,៣% នៅឆមាសទី១ និងត្រូវបានព្យាករថាមានអត្រា ៦% សម្រាប់ឆ្នាំ២០២៤ ដែលខ្ពស់ជាងឆ្នាំមុន (៥%)។ កំណើននេះត្រូវបានគាំទ្រជាចម្បងដោយកំណើនវិស័យកាត់ដេរ និងទេសចរណ៍។ ជាក់ស្តែង ការនាំចេញផលិតផលកាត់ដេរកើន ១៧,២% ការនាំចេញផលិតផលកសិកម្មកើន ៤៧,៨% ខណៈដែលចំនួនភ្ញៀវអន្តរជាតិបានកើនឡើង ២១,២%។ ដោយឡែក វិស័យសំណង់និងអចលនទ្រព្យដែលជាសសរស្តម្ភមួយក្នុងចំណោមសសរស្តម្ភទាំងបួននៃសេដ្ឋកិច្ចកម្ពុជា បន្តទទួលរងផលប៉ះពាល់ពីកត្តាខាងក្រៅ ដោយត្រូវបានរំពឹងថាមានកំណើនត្រឹម ១,៤% និង ០,៨% រៀងគ្នា។ កំណើនទាបនៃវិស័យនេះ គួបផ្សំនឹងកម្រិតទាបជាងមុននៃចំណាយរបស់ភ្ញៀវអន្តរជាតិបានប៉ះពាល់មួយផ្នែកដល់ចំណូលរបស់ប្រជាពលរដ្ឋ ដែលជះឥទ្ធិពលអវិជ្ជមានដល់ការប្រើប្រាស់ និងសកម្មភាពក្នុងវិស័យផ្សេងទៀត ជាពិសេស ការជួញដូរដុំនិងរាយ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

នៅក្នុងបរិការណ៍ដែលសេដ្ឋកិច្ចនិងនយោបាយពិភពលោកបន្តស្ថិតក្នុងស្ថានភាពមិនប្រាកដប្រជា និងដើម្បីបន្តគាំទ្រការងើបឡើងនៃសេដ្ឋកិច្ចជាតិ ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងការអនុវត្តតួនាទី-ភារកិច្ចយ៉ាងសកម្ម ក្នុងការរួមចំណែករក្សាស្ថិរភាពថ្លៃ ការធ្វើទំនើបកម្មប្រព័ន្ធទូទាត់ និងការរក្សាបានស្ថិរភាពនិងការអភិវឌ្ឍនៃប្រព័ន្ធធនាគារដ៏មានទំនុកចិត្តសម្រាប់វិនិយោគិននិងសាធារណជនទូទៅ សំដៅគាំទ្រការវិនិយោគនិងការប្រើប្រាស់។

លទ្ធផលនៃការអនុវត្តការងារទាំងនេះត្រូវបានស្តែងចេញតាមរយៈសូចនាករដូចតទៅៈ អតិផរណាមានកម្រិតជាមធ្យមត្រឹម ០,៤% ប៉ុណ្ណោះក្នុងឆមាសទី១នេះ ដោយសារការធ្លាក់ថ្លៃក្រុមទំនិញនិងសេវាពាក់ព័ន្ធនឹងប្រេងឥន្ធនៈ និងកម្រិតទាបនៃអតិផរណាម្ហូបអាហារនិងអតិផរណាស្នូល។ អត្រាអតិផរណាទាបនេះបានរួមចំណែកការពារអំណាចទិញរបស់ចំណូលប្រជាជនកម្ពុជា ស្របពេលដែលអត្រាប្តូរប្រាក់មានស្ថិរភាពក្នុងកម្រិតមធ្យម ៤.០៧៥ រៀលក្នុងមួយដុល្លារអាមេរិក ដែលបានកើនថ្លៃ ០,៤% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន។ គួររំលេចថាការរក្សាអត្រាប្តូរប្រាក់ឱ្យប្រែប្រួលទាបជាង ១% គឺជាជោគជ័យមួយរបស់កម្ពុជា បើធៀបនឹងរូបិយប័ណ្ណក្នុងតំបន់ ដូចជា រ៉ូពីឥណ្ឌូណេស៊ី ប៉េសូហ្វីលីពីន ដុងវៀតណាម បាតថៃ រីងហ្គីតម៉ាឡេស៊ី និងគីបឡាវ ដែលថយថ្លៃលើសពី ៣,៨%។ ការសម្រេចបាននេះក៏ដោយសារការអនុវត្តនយោបាយរូបិយវត្ថុយ៉ាងប្រុងប្រយ័ត្ន ដោយថ្លឹងថ្លែងពីតម្រូវការនិងការផ្គត់ផ្គង់ប្រាក់រៀលនៅក្នុងសកម្មភាពសេដ្ឋកិច្ច។ គួររំលេចថា ប្រសិទ្ធភាពនៃការប្រើប្រាស់ឧបករណ៍នយោបាយរូបិយវត្ថុនានាក៏បានចូលរួមកាត់បន្ថយការធ្វើអន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់ដែលធ្លាប់តែជាឧបករណ៍ចម្បងមួយក្នុងការរក្សាស្ថិរភាពអត្រាប្តូរប្រាក់ ហើយដែលជាទូទៅការធ្វើអន្តរាគមន៍ម្តងៗអាចធ្វើឱ្យទុនបម្រុងអន្តរជាតិថយចុះ។

គិតត្រឹមចុងឆមាសទី១នេះ ទុនបម្រុងអន្តរជាតិមានចំនួន ២០ ប៊ីលានដុល្លារអាមេរិកដែលប្រហាក់ប្រហែលនឹងចុងឆ្នាំ២០២៣ បើទោះបីជាប្រឈមនឹងភាពមិនប្រាកដប្រជាខ្ពស់នៃស្ថានភាពហិរញ្ញវត្ថុនិងសេដ្ឋកិច្ចអន្តរជាតិក៏ដោយ។ បច្ចុប្បន្ន ទុនបម្រុងអន្តរជាតិមានកម្រិតស្មើនឹង ៧ខែនៃការនាំចូលទំនិញនិងសេវាសម្រាប់គ្រាបន្ទាប់ ដែលខ្ពស់ជាងកម្រិតអប្បបរមា ៣ខែ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ ដែលត្រូវបានចាត់ទុកថាខ្ពស់គ្រប់គ្រាន់ក្នុងការរួមចំណែករក្សាជំនឿទុកចិត្តរបស់វិនិយោគិន និងសាធារណជនមកលើស្ថិរភាពសេដ្ឋកិច្ចកម្ពុជា ដែល

ជាមូលដ្ឋានចាំបាច់មួយ ក្នុងការបង្កើនប្រសិទ្ធភាពនៃការអនុវត្តនយោបាយរូបិយវត្ថុនិង អត្រាប្តូរប្រាក់។

ការពង្រឹងប្រសិទ្ធភាពនយោបាយរូបិយវត្ថុចាំបាច់ត្រូវការការប្រើប្រាស់រូបិយវត្ថុជាតិ ឱ្យបានទូលំទូលាយនៅក្នុងសេដ្ឋកិច្ច។ នៅត្រង់ចំណុចនេះ ការដាក់ចេញនូវវិធានការលើក កម្ពស់ការប្រើប្រាស់ប្រាក់រៀលនៅទាមទារការពង្រឹងនិងសម្របសម្រួលថែមទៀត ជាពិសេស ពីភាគីពាក់ព័ន្ធទាំងអស់ ក្នុងស្ថានភាពដែលកម្រិតដុល្លារូបនីយកម្មបន្តស្ថិតនៅកម្រិតខ្ពស់ នៅឡើយ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ចពិភពលោកនិងតំបន់ បានជំរុញឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុបង្កើនការប្រុងប្រយ័ត្នជាងមុនក្នុងការផ្តល់ឥណទាន ហើយស្របពេលដែល ការងើបឡើងយឺតនៃវិស័យមួយចំនួនផងនោះ កំណើនឥណទានបានថមថយជាបន្តបន្ទាប់ ដល់កម្រិតទាបក្នុងអត្រា ២,៦% ដែលជាកម្រិតទាបនៅក្នុងរយៈពេល ២ទសវត្សរ៍ចុងក្រោយ។ ជាមួយគ្នានេះ អនុបាតឥណទានមិនដំណើរការមាននិន្នាការកើនឡើងជាបន្តបន្ទាប់ដល់ ៦,៨% ចំពោះវិស័យធនាគារ និង ៨,៣% ចំពោះវិស័យមីក្រូហិរញ្ញវត្ថុ។ កម្រិតខ្ពស់នេះមួយផ្នែក បណ្តាលមកពីការថមថយល្បឿនកំណើនឥណទានផងដែរ។ ទោះយ៉ាងណា អនុបាតឥណទាន មិនដំណើរការនៅបន្តស្ថិតក្នុងកម្រិតអាចគ្រប់គ្រងបាន ហើយធនាគារជាតិនៃកម្ពុជាបាន តាមដាននិងវាយតម្លៃជាប្រចាំនូវហានិភ័យឥណទាន ក៏ដូចជាហានិភ័យពាក់ព័ន្ធនានា។ ក្នុងស្ថានភាពនេះ បទប្បញ្ញត្តិអនុគ្រោះត្រូវបានបន្តអនុវត្តដោយប្រុងប្រយ័ត្ន សំដៅរក្សាស្ថិរភាព ហិរញ្ញវត្ថុ ស្របពេលដែលការត្រួតពិនិត្យ និងការធ្វើស្ត្រេសតេស្តលើគ្រឹះស្ថានធនាគារនិង ហិរញ្ញវត្ថុត្រូវបានធ្វើឡើងជាប្រចាំ ដែលលទ្ធផលបានបង្ហាញថា ប្រព័ន្ធធនាគារកម្ពុជារក្សា បានភាពរឹងមាំ។ ជាក់ស្តែង អនុបាតភាពគ្រប់គ្រាន់នៃដើមទុនមានកម្រិតខ្ពស់ដល់ ២២,៦% សម្រាប់វិស័យធនាគារ និង ២៧,៧% សម្រាប់វិស័យមីក្រូហិរញ្ញវត្ថុ ខ្ពស់ជាងកម្រិតកំណត់ ១៥% ដែលបង្ហាញពីភាពរឹងមាំនៃដើមទុន។ ចំណែកឯអនុបាតគ្របខណ្ឌសន្ទនីយភាព មានអត្រា ១៧៩,១% ចំពោះវិស័យធនាគារ និង ២០២,៤% ចំពោះវិស័យមីក្រូហិរញ្ញវត្ថុ ខ្ពស់ ឆ្ងាយពីកម្រិតកំណត់ ១០០%ដែលបង្ហាញពីលទ្ធភាពខ្ពស់នៃការផ្តល់ឥណទាននិងការគ្រប់គ្រង ហានិភ័យសន្ទនីយភាព។ គួររំលេចថា ដើម្បីពង្រឹងការការពារហានិភ័យឥណទានក្រោយពី

ឥណទានមិនដំណើរការកើនឡើង សំវិធានធនក៏បានបង្កើន ហើយការកើនឡើងសំវិធានធននេះ គួបផ្សំនឹងការថយចុះកំណើនឥណទានបានបន្ថយលទ្ធភាពស្វែងរកប្រាក់ចំណេញគួរឱ្យកត់សម្គាល់ផងដែរ។ ក្នុងបរិការណ៍នេះ ការរួមបញ្ចូលគ្នារវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុក៏ត្រូវបានលើកទឹកចិត្ត ដើម្បីពង្រឹងភាពរឹងមាំនៃគ្រឹះស្ថាន ក៏ដូចជាប្រព័ន្ធធនាគារទាំងមូល។

ចំពោះការរក្សាស្ថិរភាពហិរញ្ញវត្ថុនេះដែរ កិច្ចការពារអតិថិជន ការចែករំលែកព័ត៌មានឥណទាន និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ ក៏ត្រូវបានពង្រឹងជាប្រចាំ ដោយបានសហការយ៉ាងជិតស្និទជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ។ លើសពីនេះ កិច្ចសហការចែករំលែកព័ត៌មានជាមួយភាគីពាក់ព័ន្ធ ក្នុងការតាមដានវឌ្ឍនភាពនៃវិស័យសំណង់និងអចលនទ្រព្យ និងការវាយតម្លៃភាពប្រទាក់ក្រឡា ដើម្បីដាក់ចេញវិធានការគ្រប់ជ្រុងជ្រោយក្នុងការគ្រប់គ្រងហានិភ័យជាប្រព័ន្ធ ដែលអាចកើតឡើងជាយថាហេតុ។

ស្របតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដែលបានចាត់ទុកបច្ចេកវិទ្យាជាអាទិភាពគន្លឹះមួយក្នុងចំណោមអាទិភាពគន្លឹះទាំងប្រាំ ធនាគារជាតិនៃកម្ពុជាបានអភិវឌ្ឍប្រព័ន្ធទូទាត់ ដើម្បីធ្វើឱ្យការទូទាត់កាន់តែងាយស្រួល សុវត្ថិភាព និងឆាប់រហ័ស មិនថាការទូទាត់ឆ្លងគ្រឹះស្ថានក្នុងស្រុក និងការទូទាត់ឆ្លងដែននោះទេ សំដៅគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល។ ក្នុងចំណោមប្រព័ន្ធទូទាត់ទាំងអស់ ប្រព័ន្ធទូទាត់បាគងបាននិងកំពុងបំពេញមុខងារកាន់តែសម្បូរបែបជូនដល់អ្នកប្រើប្រាស់ ដែលបានជំរុញការប្រើប្រាស់ប្រព័ន្ធនេះឱ្យកើនឡើងជាបន្តបន្ទាប់ និងរួមចំណែកដល់ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ និងមុខមាត់កម្ពុជានៅលើឆាកអន្តរជាតិ។ ប្រតិបត្តិការជាប្រាក់រៀលតាមប្រព័ន្ធបាគងមានចំនួនសរុប ៧៥,៥ លានប្រតិបត្តិការដែលកើន ១,៨ ដង ឬគិតជាទឹកប្រាក់ស្មើនឹង ៦៤,៩ ទ្រីលានរៀលដែលកើន ១,៤ ដង និងប្រតិបត្តិការជាប្រាក់ដុល្លារអាមេរិក ៩៩,៨ លានប្រតិបត្តិការ ឬស្មើនឹងទឹកប្រាក់ ៣៨,៨ ប៊ីលានដុល្លារអាមេរិកដែលមានកំណើន ១,៣ ដង។ បន្ថែមលើនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ឱ្យដំណើរការគម្រោងទូទាត់ឆ្លងដែនជាមួយប្រទេសថៃ ឡាវ វៀតណាម និងក្រុមហ៊ុនអន្តរជាតិយូញៀនផេ ព្រមទាំងកំពុងពង្រីកគម្រោងទូទាត់ឆ្លងដែនជាមួយប្រទេសផ្សេងទៀតក្នុងតំបន់និងដៃគូសហការនានា ដូចជា ប្រទេសចិន ជប៉ុន ឥណ្ឌា កូរ៉េ សិង្ហបុរី ម៉ាឡេស៊ី និងក្រុមហ៊ុនអាលីផេ ជាដើម។ នៅក្នុងសម័យកាលដែលបច្ចេកវិទ្យារីកចម្រើនយ៉ាងឆាប់រហ័សនេះ ឧក្រិដ្ឋកម្មសាយប័រក៏បានកើតឡើងផងដែរនិងបានក្លាយជាការព្រួយបារម្ភ

យ៉ាងខ្លាំងចំពោះការអភិវឌ្ឍសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទាំងកម្រិតមីក្រូនិងម៉ាក្រូ។ ធនាគារជាតិនៃកម្ពុជាបានពង្រឹងការគ្រប់គ្រងហានិភ័យសាយប័រឱ្យកាន់តែមានប្រសិទ្ធភាព រួមទាំងផ្តោតសំខាន់លើការការពារទិន្នន័យ និងគ្រប់គ្រងហានិភ័យនៃបច្ចេកវិទ្យាថ្មីៗ ដើម្បីធានាបាននូវភាពរឹងមាំរបស់ប្រព័ន្ធប្រតិបត្តិការធនាគារ និងជំរុញការផ្តល់សេវាធនាគារប្រកបដោយនវានុវត្តន៍។

ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ធនាគារជាតិនៃកម្ពុជាក៏បានបន្តរួមចំណែកយ៉ាងសកម្មក្នុងការពង្រឹងសមាហរណកម្ម ហិរញ្ញប្បទានប្រកបដោយចីរភាព និងសំណាញ់សុវត្ថិភាពហិរញ្ញវត្ថុតំបន់។ គួររំលេចថា ការប្រើប្រាស់រូបិយវត្ថុក្នុងស្រុកសម្រាប់ការវិនិយោគនិងពាណិជ្ជកម្មទ្វេភាគីបាននិងកំពុងក្លាយជានិន្នាការតំបន់ ជាពិសេសក្នុងក្របខណ្ឌអាស៊ាននិងអាស៊ាន+៣ ដើម្បីពង្រឹងសមាហរណកម្មនិងកាត់បន្ថយហានិភ័យនិងការខាតបង់ពីការប្រើប្រាស់ប្រាក់ដុល្លារអាមេរិក។

ដោយឡែក ក្នុងក្របខណ្ឌប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក.) បានអនុវត្តមុខងារ-ភារកិច្ចយ៉ាងខ្ជាប់ខ្ជួន តាមរយៈការអនុវត្តការងារវិភាគរបាយការណ៍ ការត្រួតពិនិត្យបុគ្គលរាយការណ៍ ការបណ្តុះបណ្តាលនិងផ្សព្វផ្សាយ និងកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ។ កិច្ចខិតខំប្រឹងប្រែងទាំងអស់នេះបានចូលរួមរក្សានិងលើកកម្ពស់តម្លាភាព និងសុវត្ថិភាពប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុឱ្យកាន់តែរឹងមាំ។

ក្រៅពីមុខងារ-ភារកិច្ចស្នូល ធនាគារជាតិនៃកម្ពុជាក៏បានយកចិត្តទុកដាក់លើការប្រែប្រួលអាកាសធាតុ ដែលបាននិងកំពុងបង្កហានិភ័យនៅគ្រប់ទីកន្លែងលើពិភពលោក។ ក្នុងទិសដៅនេះ ទុនបម្រុងអន្តរជាតិមួយផ្នែកត្រូវបានយកទៅវិនិយោគលើសញ្ញាប័ណ្ណបៃតង ដែលបង្ហាញពិភពលោកពីការយកចិត្តទុកដាក់របស់កម្ពុជាលើការទប់ទល់នឹងការប្រែប្រួលអាកាសធាតុ។ ជាមួយគ្នានេះ ធនាគារជាតិនៃកម្ពុជាចូលរួមក្នុងដំណើរការនៃការអភិវឌ្ឍគោលនយោបាយនិងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលលើការលើកកម្ពស់សេដ្ឋកិច្ចបៃតង និងការរៀបចំគំនិតផ្តួចផ្តើមនិងកិច្ចពិភាក្សានានា ទាំងក្របខ័ណ្ឌជាតិ តំបន់ និងសកល ដើម្បីជំរុញការវិនិយោគលើគម្រោងបៃតង ក៏ដូចជា ការកសាងសមត្ថភាព និងលើកកម្ពស់ចំណេះដឹងពាក់ព័ន្ធនឹងហិរញ្ញវត្ថុបៃតង។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

លទ្ធផលល្អប្រសើរទាំងនេះ អាចសម្រេចទៅបានដោយសារធនាគារជាតិនៃកម្ពុជាតែងតែអភិវឌ្ឍធនធានមនុស្សជាប្រចាំ ទាំងជំនាញនៃភាពជាអ្នកដឹកនាំនិងឯកទេសកម្ម ដែល ឯកឧត្តម ទេសាភិបាល កិត្តិយស ក៏បានចាត់ទុកការងារនេះ ជាអាទិភាពមួយដ៏ចម្បងរបស់ធនាគារជាតិនៃកម្ពុជា។ ការទទួលស្គាល់ពីសមត្ថភាពមន្ត្រីធនាគារជាតិនៃកម្ពុជាត្រូវបានឆ្លុះបញ្ចាំងតាមរយៈការអញ្ជើញទៅធ្វើជាវាគ្មិននៅក្នុងវេទិកាអន្តរជាតិធំៗទាំងតំបន់និងពិភពលោក និងការចែករំលែកបទពិសោធន៍ជាមួយប្រទេសនានា។ តាមរយៈមណ្ឌលសិក្សាបច្ចេកទេសធនាគារ ធនាគារជាតិនៃកម្ពុជាក៏បានរួមចំណែកអភិវឌ្ឍសមត្ថភាពធនធានមនុស្សផ្នែកវិស័យធនាគារនិងហិរញ្ញវត្ថុ ដោយក្នុង១ឆ្នាំៗបានផ្តល់វិញ្ញាបនបត្របញ្ចប់ការសិក្សាចំនួន ១៥០រូប ដើម្បីឆ្លើយតបនឹងការរីកចម្រើនរបស់ប្រព័ន្ធធនាគារនៅកម្ពុជា។ ម្យ៉ាងទៀត សារមន្ទីរ ស.ស.រ. កំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការបញ្ជ្រាបចំណេះដឹង ទាំងផ្នែកប្រវត្តិសាស្ត្រ សេដ្ឋកិច្ច រូបិយវត្ថុ ហិរញ្ញវត្ថុ និងធនាគារនៅកម្ពុជាជូនសាធារណជនផងដែរ។ សារមន្ទីរ ស.ស.រ. ទទួលបានការចូលទស្សនាយ៉ាងច្រើនជាបន្តបន្ទាប់ ដោយក្នុងនោះមានទាំងថ្នាក់ដឹកនាំជាន់ខ្ពស់ជាតិនិងអន្តរជាតិ និងនិស្សិត-សិស្សានុសិស្សទូទៅ ដែលឆ្នាំនេះ យើងបានទទួលអ្នកទស្សនាសរុបរហូតដល់ ២៦.៦០០ នាក់ ដែលកើនឡើង ៩៣,៦% ធៀបនឹងគ្រាដូចគ្នាឆ្នាំមុន។

ជាទីបញ្ចប់ ខ្ញុំក៏សូមសរសើរដល់ថ្នាក់ដឹកនាំ និងមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជាដែលបានចូលរួមក្នុងសកម្មភាពសង្គម សប្បុរសធម៌ និងសាសនា ជាច្រើន ដូចជា ការសហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្តដើម្បីជួយពិនិត្យនិងព្យាបាលភ្នែក-ត្រចៀកជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ ការចូលរួមក្នុងកម្មវិធីសម្ពោធឆ្លងឧបដ្ឋានសាលា កម្មវិធីសម្ពោធដាក់ឱ្យប្រើប្រាស់អាគារសិក្សា និងសមិទ្ធផលផ្សេងៗ ព្រមទាំងបានជួបសួរសុខទុក្ខ និងនាំយកអំណោយជាសម្ភារៈនិងស្បៀងអាហារមួយចំនួនចែកជូនប្រជាពលរដ្ឋដែលជួបការលំបាកក្នុងជីវភាពរស់នៅ។ សកម្មភាពទាំងនេះបានរួមចំណែកលើកកិត្តិនាមនិងគុណតម្លៃមន្ត្រី-បុគ្គលិកធនាគារជាតិនៃកម្ពុជាយើងទាំងអស់។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី!**

ដើម្បីជ្រាបពីសមិទ្ធផលលម្អិតដែលធនាគារជាតិនៃកម្ពុជាសម្រេចបាន និងទិសដៅការងារចម្បងៗ ខ្ញុំសូមឱ្យអង្គសន្និបាតត្រងត្រាប់ស្តាប់បទឧទ្ទេសនាមរបស់ថ្នាក់ដឹកនាំយើង ដែលនឹងរាយការណ៍ជូនអង្គសន្និបាតជាបន្តបន្ទាប់ពេញមួយថ្ងៃនេះ។

ខ្ញុំសូមជូនពរឱ្យអង្គសន្និបាតរបស់យើងប្រព្រឹត្តទៅប្រកបដោយជោគជ័យនិងផ្លែផ្កា។

ខ្ញុំសូមប្រកាសបើកអង្គសន្និបាតជាផ្លូវការចាប់ពីពេលនេះតទៅ។

**សូមអរគុណ!**